

ទន្លេមេគង្គ, ខ្សែទឹកខាងក្រោមទីកន្លែងបម្រុងសាងសង់ទំនប់សាយ៉ាបូរី

# ទំនប់វារីអគ្គិសនីសាយ៉ាបូរី

## ស្រមោលគម្រាមកំហែងមួយលើទន្លេមេគង្គ

*ទំនប់វារីអគ្គិសនីសាយ៉ាបូរី គឺទំនប់ដែលត្រូវបានស្នើឡើងមុនគេ ក្នុងចំណោមទំនប់ធំៗចំនួនដប់មួយ ដែលបានគ្រោងសាងសង់ នៅលើទន្លេមេគង្គខាងក្រោម ដែលស្ថិតនៅក្នុងជ្រលងភ្នំ នៅប៉ែកខាងជើង ប្រទេសឡាវ។ ប្រសិនបើទំនប់នេះ ត្រូវបានសាងសង់ នោះវានឹងបណ្តាលឱ្យមានការផ្លាស់ប្តូរ អេកូឡូស៊ីជាអចិន្ត្រៃយ៍ និងមិនអាចត្រឡប់ក្រោយបានចំពោះមហាទន្លេមួយ ដែលចិញ្ចឹមមនុស្សរាប់លាននាក់។ ការផ្លាស់ប្តូរលំនៅដ្ឋានប្រជាជនជាង ២.១០០នាក់ និង ប៉ះពាល់ប្រជាជនជាង ២០២.០០០ ដោយផ្ទាល់ និង អាចរុញច្រានឱ្យពូជមច្ឆាជាតិដ៏ល្បីល្បាញនិងជិតដាច់ពូជ ដូចជាត្រីរាជទន្លេមេគង្គជាដើម អាចឈាន ទៅដល់ការវិនាសសាបសូន្យ។*

INTERNATIONAL RIVERS people • water • life
3 S Rivers Protection Network
MY VILLAGE
CRDT CAMBODIAN RURAL DEVELOPMENT TEAM
FACT
CEPA
The NGO Forum on Cambodia

## សេចក្ដីផ្ដើម

វដ្ដលំហូរទឹកប្រចាំឆ្នាំនៃទន្លេមេគង្គក្រោម បានទ្រទ្រង់បណ្ដាញជីវិតទាំង ប្រទេសថៃ ឡាវ វៀតណាម និង កម្ពុជា។ ទន្លេមេគង្គ គឺជាទន្លេមួយក្នុងចំណោមទន្លេដែលមានជីវចម្រុះច្រើនបំផុត និង គឺជាជម្រកជលផល ទឹកសាបធំបំផុតនៃពិភពលោក។ ប៉ុន្ដែធនធានដ៏អស្ចារ្យនេះដែលផ្ដល់ប្រាក់ចំណូល និងស្បៀងអាហារ ជូនមនុស្សរាប់សិបលាននាក់ កំពុងស្ថិតក្រោមការគម្រាម កំហែងយ៉ាងធ្ងន់ធ្ងរ ដោយសារសំណើសាងសង់ទំនប់សាយ៉ាបូរីនៅលើទន្លេ។

ស្ថិតនៅក្នុងខេត្តខ្ពង់រាបនិងដាច់ស្រយាលសាយ៉ាបូរីនៅប៉ែកខាងជើងប្រទេសឡាវ ទំនប់វារីអគ្គិសនីសាយ៉ាបូរី គឺទំនប់ដែលត្រូវបានស្នើឡើងមុនគេ ក្នុងចំណោមទំនប់ធំ៧ចំនួនដប់មួយដែលត្រូវបានគ្រោងសាង សង់នៅលើទន្លេមេគង្គខាងក្រោមដែលស្ថិតនៅ ក្នុងជ្រលងភ្នំនៅប៉ែកខាងជើង ប្រទេសឡាវ។ ក្នុងខែកញ្ញា ឆ្នាំ២០១០ ទំនប់នេះ គឺជាទំនប់ទីមួយដែលត្រូវបានដាក់សុំការឯកភាព ពីរដ្ឋាភិបាលនានាក្នុងតំបន់ តាមរយៈ នីតិវិធីធ្វើសេចក្ដីសម្រេចចិត្តក្នុងតំបន់មួយ ដែលមានឈ្មោះថា " នីតិវិធីក្នុការជូនដំណឹង ការពិគ្រោះយោបល់ ជាមុន និងកិច្ចព្រមព្រៀង (PNPCA)" ដែលត្រូវបានសម្របសម្រួលដោយគណៈកម្មការទន្លេមេគង្គ។

ប្រសិនបើត្រូវបានឯកភាព ទំនប់នេះមុខជាធ្វើឱ្យ មានការខូចខាតបរិស្ថានធ្ងន់ធ្ងរ ចំពោះធនធានធម្មជាតិ និងជលផលនៃទន្លេនេះ ទាំងក្នុងមូលដ្ឋាន និងក្នុងអាងទន្លេទាំងមូល។ ប្រជាជនប្រហែល ២.១០០ នាក់នឹងត្រូវរើលំនៅដ្ឋាន ដោយសារ គម្រោង ហើយប្រជាជនជាង ២០២.000 ដែល រស់នៅជិតទំនប់នឹងទទួល រងផលប៉ះពាល់ចំពោះ មុខរបរប្រាក់ចំណូល និង សន្ដិសុខស្បៀងរបស់ខ្លួន ដោយសារការបាត់បង់ដីកសិកម្ម និងសួនបន្លែតាម ដងទន្លេរបស់ខ្លួន និងការបញ្ចប់ការរែងមាស នៅក្នុងទន្លេ និង ភាពកាន់តែលំបាកក្នុងការ ចូលរកអនុផលព្រៃឈើ ដូចជា ត្រយូងចេកព្រៃ និងផ្ដៅជាដើម។ ការផ្លាស់ប្ដូរ ដែលបណ្ដាលមក ពីទំនប់ចំពោះ ជីវចម្រុះនិងជលផលទន្លេ នឹង ជះឥទ្ធិពលលើអាងទន្លេទាំងមូល ដែលប៉ះពាល់ ប្រជាជនរាប់លាននាក់។

## ទំនប់សាយ៉ាបូរី

ទំនប់សាយ៉ាបូរីលាតសន្ធឹងកាត់ទទឹងទន្លេមេគង្គទាំងមូល មានប្រវែង ៨១០ ម៉ែត្រ និងមានទីតាំងស្ថិតនៅត្រង់កន្លែងទឹកហូរខ្លាំង កែងលួង ដែលមានចម្ងាយប្រមាណជា ៣០ គីឡូម៉ែត្រនៅ ខាងកើតពីទីរួមខេត្តសាយ៉ាបូរី នៅប៉ែកខាងជើងប្រទេសឡាវ។ គម្រោងនេះត្រូវបានរំពឹងថានឹងផលិតអគ្គិសនី កម្លាំង ១.២៦០ មេហ្គាវ៉ាត់ ដែលក្នុងនោះ ប្រហែល ៩៥% នឹងត្រូវ នាំចេញទៅកាន់ប្រទេសថៃ។

រដ្ឋាភិបាលឡាវបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់មួយ ជាមួយក្រុមហ៊ុន អភិវឌ្ឍន៍គម្រោង ពោលគឺក្រុមហ៊ុន Ch. Karnchang Public Company នៃប្រទេសថៃ កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៧។




ការពិភាក្សាកំពុងដំណើរការ ជាមួយមុខសញ្ញាវិនិយោគិននានា រួមទាំង រដ្ឋាភិបាលឡាវ ក្រុមហ៊ុន Ratchaburi Electricity Generating Holding Company និង ក្រុមហ៊ុន EGAT International Company ។ ទំនប់នេះ នឹងត្រូវ ចំណាយពេល ប្រាំបីឆ្នាំសម្រាប់សាងសង់ និងត្រូវចំណាយ ប្រាក់ប្រមាណ ជា ៣,៥ ពាន់លាន ដុល្លារអាមេរិក ។

ក្រោយពេលមានអនុស្សរណៈនៃការយោគយល់កិច្ចព្រមព្រៀងគម្រោងមួយត្រូវបានចុះហត្ថលេខា រវាង រដ្ឋាភិបាលឡាវ និង ក្រុមហ៊ុន Ch. Karnchang ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ខណៈដែលរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) នៃគម្រោង ត្រូវបានដាក់ជូនរដ្ឋាភិបាលឡាវដើម្បីអនុម័ត កាលពីខែ កុម្ភៈ ឆ្នាំ ២០១០។ បន្ទាប់មក អនុស្សរណៈនៃការយោគយល់មួយសម្រាប់កិច្ចព្រមព្រៀងទិញអគ្គិសនី ត្រូវបានចុះហត្ថលេខារវាងអាជ្ញាធរផលិតអគ្គិសនីថៃ (EGAT) និង រដ្ឋាភិបាលឡាវ ក្នុងខែ កក្កដា ឆ្នាំ ២០១០ ដែលនឹងអនុញ្ញាតឱ្យអាជ្ញាធរផលិតអគ្គិសនីថៃ (EGAT) ទិញអគ្គិសនីកម្លាំង ១.២២០ មេហ្គាវ៉ាត់ ក្នុងតម្លៃ ២,១៩៩ បាតក្នុងមួយគីឡូវ៉ាត់ម៉ោង តាមរយៈខ្សែបញ្ជូនអគ្គិសនីមួយប្រវែង ២០០ គីឡូម៉ែត្រ ដែលនឹងធ្វើដំណើរពីទំនប់សាយ៉ាបូរីទៅកាន់ខេត្តឡើយ (Loei) នៅភូមិភាគឦសានប្រទេសថៃ ។

ថ្វីបើឯកសារគម្រោងនានា ដូចជារបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ជាដើម នៅមិនទាន់បានផ្សព្វផ្សាយ ជាសាធារណៈក្តី ក៏គម្រោងសង្ឃឹមថានឹងទទួលបានការយល់ព្រមពីរដ្ឋាភិបាលនៃ ប្រទេស កម្ពុជា ឡាវ ថៃ និង វៀតណាម មុនដំណាច់ខែ មីនា ឆ្នាំ ២០១១។ ស្របតាមកិច្ចព្រមព្រៀង ទន្លេមេគង្គឆ្នាំ ១៩៩៥ បណ្តាប្រទេសតាមទន្លេមេគង្គក្រោមទាំងនេះ បានអនុម័តពិធីសារមួយដែលតម្រូវឱ្យពួកគេជូនដំណឹង ពិគ្រោះយោបល់ជាមុន និង កិច្ចព្រមព្រៀងជាមួយប្រទេសជិតខាងរបស់ខ្លួនលើសំណើ គម្រោងសាងសង់លើទន្លេនេះ។ ក្នុងខែ កញ្ញា ឆ្នាំ ២០១០ ទំនប់សាយ៉ាបូរីក្លាយជាទំនប់ទីមួយដែលបានចាប់ផ្តើមនីតិវិធីសម្រាប់ការជូនដំណឹង ពិគ្រោះយោបល់ជាមុន និង កិច្ចព្រមព្រៀង (PNPCA) ។ ការប្រកាសនេះ ត្រូវបានធ្វើ បីសប្តាហ៍ មុនពេលបញ្ចេញរបាយការណ៍ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រ ស្តីអំពីផលប៉ះពាល់ផ្នែកបរិស្ថាន របស់ទំនប់វារីអគ្គិសនី តាម ដងទន្លេមេនៃទន្លេមេគង្គ (SEA) ដែលបានផ្តល់អនុសាសន៍ឱ្យពន្យារពេល ១០ឆ្នាំ មុននឹងធ្វើសេចក្តីសម្រេចចិត្តឱ្យមានទំនប់ លើទន្លេមេនៃទន្លេមេគង្គ រួមទាំងទំនប់សាយ៉ាបូរីផលដែរ នេះដោយសារហានិភ័យ និងផលប៉ះពាល់ដ៏ធំធេងពាក់ព័ន្ធនឹងគម្រោងទាំងនេះ។ ទោះបីជាមានអនុសាសន៍ដ៏ច្បាស់លាស់នេះក្តី ក៏ដំណើរការធ្វើសេចក្តីសម្រេចចិត្ត នៅតែបន្តបោះជំហានទៅមុខ។

# ការគម្រាមកំហែងចំពោះជីវចម្រុះជលជាតិ និង ផលិតភាពជលផល

ប្រសិនបើត្រូវបានសាងសង់ ទំនប់សាយ៉ាប៊ូរីមុខជាធ្វើឱ្យខូចខាតជាអចិន្ត្រៃយ៍ដល់ជម្រក និងប្រព័ន្ធអេកូឡូស៊ី នៃទន្លេមេគង្គ ដែលជាហេតុធ្វើឱ្យមានហានិភ័យដល់ជីវចម្រុះដ៏សម្បូណ៌បែបនៃទន្លេមេគង្គ។ យ៉ាងហោចណាស់មច្ឆាជាតិចំនួន ៤១ប្រភេទ អាចត្រូវដាច់ពូជដោយសារការផ្លាស់ប្តូរដ៏ធ្ងន់ធ្ងរចំពោះទីជម្រករបស់វា។ ទំនប់សាយ៉ាប៊ូរីក៏នឹងរាំងខ្ទប់ផ្លូវធ្វើដំណើរបម្លាស់ទី និងវដ្តជីវិត ដ៏សំខាន់របស់មច្ឆាជាតិយ៉ាងហោចណាស់ ២៣ប្រភេទ ដែលធ្វើដំណើរទៅប៉ែកខាងលើនៃទន្លេមេគង្គ នៅល្វងប្រាបាងនៅឡាវ និង ឈៀងខង និង ឈៀងសែន នៅប្រទេសថៃ។ មច្ឆាជាតិមួយប្រភេទ ដែលអាចត្រូវដាច់ពូជគឺត្រីរាជទន្លេមេគង្គ។



ទំនប់សាយ៉ាប៊ូរីនឹងកាត់បន្ថយជលផលមច្ឆាជាតិ និង ជីវចម្រុះមច្ឆាជាតិ។ ប្រការនេះនឹងមានផលប៉ះពាល់ផ្នែកចំណាយខ្លាំងលើជីវភាព និងសន្តិសុខស្បៀងរបស់ប្រជាជនរាប់លាននាក់ដែលរស់នៅតាមដងទន្លេនេះ។

ទំនប់នេះ នឹងប៉ះពាល់ជាអវិជ្ជមាន លើប្រព័ន្ធអេកូឡូស៊ីដ៏សាំញ៉ាំ នៃទន្លេមេគង្គ បន្ថែមពីលើផលប៉ះពាល់ ដែលធ្លាប់មានពីទំនប់នានា ដែលបានសាងសង់នៅប៉ែកខាងលើនៃប្រទេសចិន។ ឧទាហរណ៍ ការផលិត ខាយ *(Kai)* ក្នុងមូលដ្ឋាននឹងត្រូវបំផ្លាញ ដោយអាងទំនប់។ *ខាយ* គឺជាសារ៉ាយទឹកសាបដែលជាអាហារដ៏សំខាន់ មួយសម្រាប់មច្ឆាជាតិ ក៏ដូចជាមុខម្ហូបដ៏ល្បីមួយនៅល្វង ប្រាបាង។ សម្រាប់ស្ត្រីឡាវ នៅជិត ទីតាំងទំនប់ *ខាយ* គឺជាប្រភពនៃប្រាក់ចំណូលមួយដ៏សំខាន់របស់ពួកគេនៅក្នុងរដូវប្រាំង នៅពេលដែល ទឹកទន្លេមេគង្គ ស្រកចុះរាក់ និង ថ្លា ដែលអនុញ្ញាត ឱ្យរុក្ខជាតិ *ខាយ* ដុះ។



ទំនប់សាយ៉ាប៊ុរីនឹងគម្រាមកំហែងដល់ចំនួនត្រីរាជទន្លេមេគង្គជិតដាច់ពូចដែលនៅសេសសល់។ រក្សាសិទ្ធិរូបថតដោយ Zeb Hogan។

ទោះបីជាមានផលប៉ះពាល់ធំធេង ចំពោះជលផលក្នុងតំបន់ក្តី ក៏អ្នកអភិវឌ្ឍគម្រោងបានព្រងើយកន្តើយចំពោះមតិឯកភាពវិទ្យាសាស្ត្រ និងបានមើលស្រាលលើការគម្រាមកំហែងដ៏ធ្ងន់ធ្ងរ នេះ ដោយអះអាងថា ជណ្តើរមច្ឆាជាតិពីរដែលត្រូវបានដាក់ បញ្ចូលក្នុងប្លង់សាងសង់ទំនប់ នឹងកាត់បន្ថយផលប៉ះពាល់លើ ជលផល។ ប៉ុន្តែ ចាប់តាំងពីខែ កញ្ញា ឆ្នាំ ២០០៨ និង ថ្មីៗបំផុតនេះ នៅក្នុងរបាយការណ៍ការប៉ាន់ប្រមាណ ជាយុទ្ធសាស្ត្រ ស្តីអំពីផលប៉ះពាល់ផ្នែកបរិស្ថានរបស់ទំនប់វារីអគ្គិសនី តាមដងទន្លេមេនៃទន្លេមេគង្គ (SEA) របស់គណៈកម្មការទន្លេមេគង្គ អ្នកឯកទេសផ្នែកជលផលដ៏ល្បីល្បាញមួយក្រុម បានបញ្ជាក់យ៉ាងច្បាស់ថា ជណ្តើរមច្ឆាជាតិនឹង មិនមានប្រសិទ្ធភាពទេ សំរាប់ការបំលាស់ទីមច្ឆាជាតិចំនួនច្រើននៃទន្លេនេះទេ។ សូម្បីតែច្រកមច្ឆាជាតិធ្វើ ដំណើរត្រូវបាន រៀបចំ ធ្វើសម្រាប់ពូជត្រី ជាក់លាក់មួយចំនួនក្តី ក៏របាយការណ៍ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រ ស្តីអំពីផលប៉ះពាល់ ផ្នែកបរិស្ថានរបស់ទំនប់វារីអគ្គិសនី តាមដងទន្លេមេ

នៃទន្លេមេគង្គ (SEA) បានសង្កត់ធ្ងន់ថា កម្ពស់ ៣២ម៉ែត្រ នៃទំនប់សាយ៉ាបូរីគឺខ្ពស់ជាងកម្ពស់អតិបរមា ដែលមច្ឆាជាតិអាចធ្វើការ បំលាស់ទីបាន ។

## ប្រជាជន និង មុខរបរ

ស្ថិតនៅចម្ងាយប្រមាណ ១៥០ គីឡូម៉ែត្រ ខាងក្រោមទីរួមខេត្តលួងប្រាបាង ជាទីតាំង បេតិកភណ្ឌយូណេស្កូពិភពលោកមួយ (UNESCO) ។ ទំនប់សាយ៉ាបូរីនឹងគម្រាម កំហែងការរើលំនៅឋានប្រជាជនជាង ២.១០០នាក់នៅក្នុងភូមិចំនួនដប់ ។ អាងទឹក នៃទំនប់នេះមានចំងាយត្រឹមតែ ៤៨ គីឡូម៉ែត្រ ប៉ុណ្ណោះ ពីអាងមកដល់ទីក្រុង ប្រវត្តិសាស្រ្តនេះ ។ ទំនប់ក៏នឹងប៉ះពាល់ដោយផ្ទាល់ផងដែរដល់ជីវិតរបស់ប្រជាកសិករ និងអ្នកនេសាទយ៉ាង ហោចណាស់ចំនួន ២០២.១៩៨ នាក់ដែលរស់នៅក្នុងស្រុកចំនួនបួន ក្នុងប្រទេសឡាវក៏ដូចជាប្រជាជនជាច្រើន នាក់ទៀតនៅក្នុងអាងទន្លេទាំងមូល ។

អ្នកនេសាទ និងប្រជាកសិករដែលរស់នៅជិតទីតាំង ទំនប់ រួមមានក្រុមជាតិពន្ធផ្សេងៗគឺបំពេញសេចក្តីត្រូវការប្រចាំថ្ងៃរបស់ខ្លួន តាមរយៈការរកត្រី ធ្វើស្រែ រែងមាស រកអនុផលព្រៃឈើ និងដាំបន្លែ នៅតាមមាត់ទន្លេ។ ជីវភាព និងវដ្តជីវិតដ៏ពិសេសរបស់ សហគមន៍ទាំងនេះ មុខជាត្រូវផ្លាស់ប្តូរជារៀងរហូត ដោយផលប៉ះពាល់របស់ទំនប់នេះ តាមរយៈការផ្លាស់ លំនៅដ្ឋាន ឬផលប៉ះពាល់ដោយប្រយោល ដូចជាការ បាត់បង់ដីធ្លី និងលទ្ធភាព រកធនធានធម្មជាតិ ។

### ទេសចរណ៍បរិស្ថានក្នុងខេត្តសាយ៉ាបូរី

ខេត្តសាយ៉ាបូរី មានឈ្មោះល្បីល្បាញដោយសារទេសភាព ឡើងទួល ចុះទួល ភ្នំដ៏ស្អាត និង សួនផ្កា ពិធីបុណ្យដ៏រី និងសក្តានុពលដ៏ខ្ពស់ សម្រាប់ទេសចរណ៍ធម្មជាតិរបស់ខេត្ត។ ប្រជាជនមូលដ្ឋានជាច្រើន ទៅទស្សនាផាដែង (Pha Daeng) ដែលជារូងដ៏តូច និងស្អាតមួយដែលមានអក្សរបុរាណ លំអជញ្ជាំងរូង ដែលស្ថិតនៅជិតទីទាំង គម្រោង។ ការជិះទូកកំសាន្ត តាមទន្លេមេគង្គឆ្លងកាត់ត្រង់នេះ ក៏គឺជាសកម្មភាពទេសចរណ៍ កំពុង កើនឡើងមួយផងដែរ។ ទេសភាពដ៏ស្រស់បំព្រង និង បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ដ៏មានតម្លៃរបស់ខេត្ត នឹងត្រូវបាត់បង់ជារៀងរហូត ដោយការ សាងសង់ និងប្រតិបត្តិការទំនប់ ។

ទោះបីជាមានផលប៉ះពាល់ធ្ងន់ធ្ងរទាំងនេះក្តី ក៏ប្រជាជនមូលដ្ឋាន នៅក្នុងតំបន់រងផលប៉ះពាល់នៅ ប្រទេសឡាវ និង ប្រទេសជិតខាង បានទទួលព័ត៌មានតិចតួចឬមិនបានទទួលព័ត៌មានអំពីទំនប់នេះទេ។ ប្រជាជនដែលត្រូវរងផលប៉ះពាល់អរិជ្ជមានជាងគេ នៅប្រទេសឡាវ បានទទួលព័ត៌មានមិនពេញលេញពីអ្នកអភិវឌ្ឍគម្រោង និងមានឱកាសតិចតួចដើម្បីសម្តែងការបារម្ភរបស់ខ្លួន។ ប្រជាជននៅខាងលើ និងខាងក្រោម ខ្សែទឹកមាននៅប្រទេសថៃ កម្ពុជា និង វៀតណាម បានទទួលព័ត៌មានកាន់តែស្តួចស្តើង ទោះបីជាមានការប៉ាន់ ប្រមាណថាមានផលប៉ះពាល់ឆ្លងព្រំដែនក្តី។

សម្រាប់អ្នកភូមិនៅស្រុកសាយ៉ាបូរី ណាម លួងប្រាបាង និង ចំម៉េផេត ដែលដីធ្លី និងលំនៅឋានរបស់ខ្លួន នឹងត្រូវជន់លិចដោយទំនប់នឹងត្រូវផ្លាស់ទីលំនៅ ។ អនាគតរបស់ពួកគេគឺមានលក្ខណៈគួរឱ្យបារម្ភ ជាពិសេសសម្រាប់គ្រួសារមួយចំនួន នៅក្នុងស្រុកណាម ដែលនឹងត្រូវផ្លាស់លំនៅឋានបួនលើក ក្នុងរយៈពេល ១៥ឆ្នាំ ក្រោយពេលត្រូវផ្លាស់ទីលើកទីមួយពីខ្ពស់រាបមក

ដីទំនាប ហើយបន្ទាប់មកត្រូវរើលំនៅឋានពីរដងទៀត ដោយសារទឹកជំនន់ដោយមិនបានទទួលជំនួយអ្វីសោះ។ កម្មវិធីផ្លាស់លំនៅដ្ឋាន មានគុណភាពទាប ផលប៉ះពាល់បរិស្ថានខ្លាំង និងកង្វះជម្រើសជីវភាពសម្រាប់សហគមន៍ដែលត្រូវផ្លាស់ទីលំនៅ និងសហគមន៍ រងផលប៉ះពាល់គឺជារឿងធម្មតានៅប្រទេសឡាវ។ ជាមួយបញ្ហាមិនទាន់បានដោះស្រាយជាច្រើននៅប្រទេសឡាវ រួមទាំងកង្វះសមត្ថភាពស្ថាប័ន និងឆន្ទៈនយោបាយដើម្បីប្រតិបត្តិច្បាប់បរិស្ថាន និងដើម្បីបំពេញការប្តេជ្ញាគាំពារសង្គមក្នុងកម្រិត អប្បបរមា សហគមន៍សាយ៉ាបូរីទំនងជានឹងធ្លាក់ចូលក្នុងគន្លងរបស់សហគមន៍ក្រីក្រផ្សេងទៀតដែលរងផលប៉ះពាល់ពីទំនប់។

## ការខាតបង់សម្រាប់មនុស្សជាច្រើន, ផលប្រយោជន៍សម្រាប់មនុស្សមួយចំនួនតូច

រដ្ឋាភិបាលឡាវជឿថាទំនប់សាយ៉ាបូរីនឹងគឺជាប្រភពដ៏សំខាន់ មួយនៃប្រាក់ចំណូលរបស់រដ្ឋាភិបាល ជួយទាក់ទាញការវិនិយោគបរទេស និងជម្រុញកំណើនសេដ្ឋកិច្ចជាតិ។ ប៉ុន្តែអំណះអំណាងនេះ គឺមិនត្រឹមត្រូវព្រោះការអះអាងនេះគឺមិនទាន់បានប្រៀបធៀប ពីផលប្រយោជន៍ ដែលទន្លេមេគង្គបានផ្តល់លើផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌ សម្រាប់ ប្រទេសឡាវ និង តំបន់ទន្លេមេគង្គ។ ធនធានដ៏សម្បូរណ៍បែបនៃទន្លេនេះ គឺជួយបំពេញសន្តិសុខស្បៀង ផ្តល់ជីមានជីជាតិ និងទឹកសម្រាប់ស្រោចស្រពកសិកម្ម។ ធនធាន ទាំងនេះ គឺសុទ្ធតែអាចកកើតឡើងវិញ និងផលិតបានដោយឥតបង់ថ្លៃ ប្រសិនបើ មិនមានការបំផ្លាញប្រព័ន្ធអេកូឡូស៊ី ទន្លេ។



ការរែងមាសនៅក្នុងរដូវប្រាំង គឺជាប្រភពដ៏ សំខាន់មួយនៃប្រាក់ចំណូលរបស់អ្នកភូមិឡាវ ជាច្រើន ជាពិសេសស្ត្រី ដែលអាចរកបានដល់ ៨,៥០ដុល្លារអាមេរិកក្នុងមួយគ្រួសារក្នុងមួយថ្ងៃ។ ការរែងមាសនឹងមិនអាចធ្វើតទៅទៀតបានទេ ប្រសិនបើទំនប់សាយ៉ាបុរីត្រូវបានសាងសង់។

ថ្លៃចំណាយពិតប្រាកដរបស់គម្រោងនេះគឺមិនត្រូវបានគណនា ឱ្យបានគ្រប់ជ្រុងជ្រោយទេ។ នេះគឺដោយការខកខានមិនបាន កំណត់ថ្លៃចំណាយពិតប្រាកដនៃទំនប់ពាក់ព័ន្ធនឹងការខូចខាតខាងបរិស្ថាននិងសង្គមដែលនឹងកើតមានចំពោះប្រជាជនរាប់លាននាក់ និងកម្មវិធីសង្គម និងបរិស្ថាននានាដែលនឹងមានលក្ខណៈ ចាំបាច់ ដើម្បីសម្រាល និងសងការខូចខាតនេះ ។

ថ្លៃចំណាយ និង អត្ថប្រយោជន៍ផ្នែកសង្គមនិងបរិស្ថាននៃទំនប់សាយ៉ាបូរី ទំនងជានឹងមិនត្រូវបានចែកចាយឱ្យស្មើគ្នាទេ ទាំងរវាងប្រជាជន និងរវាងបណ្តាប្រទេសនៅតាមទន្លេមេគង្គក្រោម។ ផលប៉ះពាល់នៃទំនប់នេះ មុខជាប៉ះពាល់ដល់សហគមន៍នានា ដែលជីវភាពរបស់ខ្លួនពឹងអាស្រ័យលើធនធានធម្មជាតិនៃទន្លេ។ ជាងនេះទៀត តំបន់ដែលពួកគាត់រស់នៅជាទីតាំង ដែលមានភាព ក្រីក្រខ្ពស់ផងដែរ។ ហេតុដូច្នេះ ប្រការនេះ គម្រាមកំហែងដល់វឌ្ឍនភាពរបស់ប្រទេសឡាវក្នុងការសម្រេចបានគោលដៅ កាត់បន្ថយភាពក្រីក្រ និង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន។

**ទំនប់ល្បាក់វារីអគ្គិសនីលើទន្លេមេគង្គនៅភាគខាងជើងប្រទេសឡាវ**

ក្នុងចំណោមទំនប់គ្រោងសាងសង់លើទន្លេមេគង្គលើទាំងដប់មួយ ទំនប់សាយ៉ាបូរីគឺជាគម្រោងមួយនៃគម្រោងវារីអគ្គិសនី ចំនួនប្រាំមួយ ដែលគ្រោងសាងសង់លើ កំណាត់ទន្លេមេគង្គប្រវែង ១.១០០ គីឡូម៉ែត្រ ដែលផ្តើមចេញពីឈៀងសែននៅប៉ែកខាងជើងប្រទេសថៃ ទៅដល់វៀងច័ន្ទក្នុងប្រទេសឡាវ។ តំបន់នេះមានឈ្មោះល្បីដោយសារភ្នំនិងជ្រលងចង្អៀតបត់បែននិងចោតរបស់វា។ ទំនប់ល្បាក់ទឹកនេះនឹងផលិតអគ្គិសនី កម្លាំងជិត ៧.000 មេ៉ហ្គាវ៉ាត់ ដោយអគ្គិសនីភាគច្រើនត្រូវនាំចេញទៅប្រទេសថៃ និង វៀតណាម។

ទំនប់ល្បាក់វារីអគ្គិសនីលើទន្លេមេគង្គនៅភាគខាងជើងប្រទេសឡាវ ត្រូវបានផ្សព្វផ្សាយថា មានប្រយោជន៍សម្រាប់តំបន់ តាមរយៈកំណើនការវិនិយោគបរទេសផ្ទាល់ និង ការធ្វើនាវាចរកាន់តែប្រសើរឡើងតាមទន្លេនេះ។ ប៉ុន្តែ ការពិតនៃគម្រោងទាំងនេះ បង្ហាញអនាគតខ្មៅងងឹតច្រើនជាង។ ដោយកាត់ផ្តាច់កំណាត់ខាងលើ និងខាងក្រោមនៃទន្លេមេគង្គ ទំនប់ទាំងប្រាំមួយនេះនឹងនាំឱ្យ មានការផ្លាស់ប្តូរដែលបំផ្លិចបំផ្លាញប្រព័ន្ធអេកូឡូស៊ីជលជាតិ។ របាយការណ៍ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រស្តីអំពីផលប៉ះពាល់ផ្នែក បរិស្ថានរបស់ទំនប់វារីអគ្គិសនី តាមដងទន្លេមេនៃទន្លេមេគង្គ ដែលត្រូវបានផ្សព្វផ្សាយក្នុង ខែតុលា ឆ្នាំ ២០១០ បង្ហាញថាប្រហែល ៨0% នៃកំណាត់ទន្លេនេះនឹងត្រូវប្រែក្លាយទៅជាអាងនិយតកម្មមួយចំនួនដែលជន់លិចដីកសិកម្ម និងសួនបន្លែតាមមាត់ទន្លេដ៏មានតម្លៃ។ម្យ៉ាងទៀត របាយការណ៍និយាយថា តំបន់នេះនឹងក្លាយជា "ក្រខ្សត់ធ្ងន់ធ្ងរ" តាមរយៈផលប៉ះពាល់ជីវសាស្ត្រលើតំបន់ត្រីពង និងបង្កើតកូន ដែលចាំបាច់សម្រាប់វដ្តជីវិតនៃជលផល។ ប្រការនេះនឹងនាំឱ្យមានការបាត់បង់ផលចាប់បានក្នុងធម្មជាតិប្រមាណជាពី ២៧0.000 ដល់ ៦00.000 តោនក្នុងមួយឆ្នាំ ដែលស្មើនឹងការបាត់បង់ប្រូតេអ៊ីនប្រចាំឆ្នាំស្មើនឹង ៦0% នៃផលិតកម្មបសុសត្វ បច្ចុប្បន្ននៅប្រទេសឡាវ។ ចំពោះមុខវិសាលភាពនៃផលប៉ះពាល់ផ្ទាល់ទាំងនេះលើប្រព័ន្ធអេកូឡូស៊ី និងសុខុមាលភាពរបស់ប្រជាជន ទំនប់ទាំងនេះមិនទំនងជារួមចំណែកដល់ការអភិវឌ្ឍតំបន់ទេ ប៉ុន្តែផ្ទុយទៅវិញ ធ្វើឱ្យត្រឡប់ក្រោយវិញនូវសមិទ្ធផលជាច្រើនក្នុង តំបន់ដែលសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រ ការកែលម្អសុខភាព និងអាហារូបត្ថម្ភ ព្រមទាំងការអភិវឌ្ឍន៍ប្រកបដោយ និរន្តរភាពមកដល់ពេលនេះ។

## តួនាទីដ៏សំខាន់របស់ប្រទេសថៃ

ដោយមានតំរូវការទីផ្សារថាមពលអគ្គិសនីដែលផលិតដោយទំនប់សាយ៉ាបូរី អ្នកធ្វើសេចក្តីសម្រេច ចិត្ត នៅក្នុងក្រសួងថាមពល និងក្រុមហ៊ុនអគ្គិសនី EGAT នៃប្រទេសថៃនឹងមានតួនាទីដ៏សំខាន់មួយក្នុង ការកំណត់ថាតើទំនប់សាយ៉ាបូរីគប្បីត្រូវសាងសង់ឬទេ។ លើសពីនេះទៀត ក្រុមហ៊ុនអភិវឌ្ឍធំជាងគេ ពោលគឺ Ch.Karnchang គឺជាក្រុមហ៊ុនសំណង់ចុះបញ្ជីសាធារណៈធំបំផុតទីពីរ របស់ប្រទេសថៃ។ ជាងនេះទៀត ធនាគារថៃក៏កំពុងពិចារណាផ្តល់ប្រាក់កម្ចីដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងនេះដែរ ដូចជា ធនាគារកសិករ (Kasikorn) ធនាគារបាងកក ធនាគារក្រុងថៃ និងធនាគារសៀមពាណិជ្ជ បើទោះជាគម្រោងនេះ មិនបានបំពេញ តាមការទទួលខុសត្រូវសាជីវកម្ម និងសង្គមរបស់ធនាគារទាំងនេះក្តី។

ប្រទេសថៃ ដែលបានអភិវឌ្ឍវារីអគ្គិសនីក្នុងស្រុកភាគច្រើនរបស់ខ្លួនរួចហើយ គឺប្រឈមមុខនឹងការប្រឆាំងខ្លាំងចំពោះគម្រោងបន្ថែមទៀត នៅក្នុងស្រុកដោយសារប្រវត្តិគម្រោងនានាកន្លងមក ដូចជា ទំនប់ ប៉ាក់មូន (Pak Mun Dam) ជាដើម។ ជំនួសមកវិញ ថៃកាន់តែព្យាយាមនាំចូលអគ្គិសនីពីប្រទេសជិតខាង ដែលប្រទេសទាំងនោះ សង្គមស៊ីវិលនៅទន់ខ្សោយ ហើយការ ជំទាស់មិនឱ្យមានទំនប់ត្រូវបានរារាំង។ ក្រុមសង្គមស៊ីវិលថៃ បានចោទសួរផែនការអភិវឌ្ឍន៍អគ្គិសនីរបស់ប្រទេសថៃដែលជម្រុញយ៉ាងខ្លាំងនូវការអភិវឌ្ឍន៍ រោងចក្រផលិតអគ្គិសនីថ្មីៗខ្នាតធំ ដូចជារោងចក្រអគ្គិសនីដើរដោយ

ប្រេងឥន្ធនៈ និងទំនប់វារីអគ្គិសនីជាដើម។ ពួកគេសន្និដ្ឋានថាតម្រូវការអគ្គិសនីអនាគតត្រូវបានប៉ាន់ស្មានលើស និងថាសក្តានុពលសម្រាប់វិធានការ ប្រសិទ្ធភាពថាមពល ដូចជាថាមពលកកើតថ្មី និងជម្រើសថាមពលបែបវិមជ្ឈការនៅប្រទេសថៃគឺមាន លក្ខណៈមាំមួន និងអាចដំណើរការ បានប្រសិនបើការរៀបចំផែនការថាមពលបន្តធ្វើកំណែទម្រង់។

## ការពារអនាគតនៃទន្លេមេគង្គ

នីតិវិធីធ្វើសេចក្តីសម្រេចចិត្តក្នុងតំបន់ដែលត្រូវបានជួយសម្របសម្រួលដោយគណៈកម្មការទន្លេមេគង្គ លើទំនប់សាយ៉ាបូរីត្រូវបានរំពឹងថា នឹងប្រកាសសេចក្តីសម្រេចចិត្តមួយនៅដើមខែ មីនា ឆ្នាំ ២០១១។ ការបារម្ភធ្ងន់ធ្ងរនេះ ត្រូវបានសម្តែងដោយក្រុមមូលដ្ឋាននានា នៅក្នុងតំបន់មេគង្គទាំងមូល និងដោយសម្ព័ន្ធ ការពារទន្លេមេគង្គដែលជាបណ្តាញមួយនៃអង្គការក្នុងស្រុក តំបន់ និង អន្តរជាតិ និងបុគ្គល។ ក្រុមសង្គមស៊ីវិលទាំងនេះក៏បានអំពាវនាវផងដែរដល់គណៈកម្មការទន្លេមេគង្គ និងអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងតំបន់ សូមឱ្យផ្អាកទំនប់សាយ៉ាបូរី ទន្ទឹមគ្នានឹងការប្រកាន់យកអនុសាសន៍នៃរបាយការណ៍ ប៉ាន់ប្រមាណជាយុទ្ធសាស្ត្រ ស្តីអំពីផលប៉ះពាល់ផ្នែកបរិស្ថានរបស់ទំនប់វារីអគ្គិសនីតាមដងទន្លេមេនៃទន្លេមេគង្គ ដោយឱ្យពន្យារពេល លើការសម្រេចចិត្តឱ្យមានការសាងសង់ទំនប់ទាំង១១លើទន្លេមេនៃទន្លេមេគង្គនេះ សម្រាប់រយៈពេលមួយ យ៉ាងហោចណាស់ដប់ឆ្នាំ។

ទន្លេមេគង្គមួយដែលហូរដោយសេរី តំណាងឱ្យសន្តិសុខ និងវិបុលភាពសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត។ ចន្លោះប្រហោងដ៏ធំនៃការយល់ដឹង និងការខកខានមិនបានបំពេញតាមបទដ្ឋានស្តង់ដារ អន្តរជាតិលើការអនុវត្តន៍ប្រសើរបំផុត ដូចជាតម្លាភាព ការចូលរួមសាធារណៈ គណនេយ្យភាព អាចធ្វើឱ្យមានការសម្រេចចិត្តខុសព្រោះមិនមានព័ត៌មានពេញលេញ។ ហើយការសម្រេចចិត្តនេះ អាចនឹងប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដោយសារទន្លេមេគង្គនេះ បានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនជូនដល់ ប្រជាជនរាប់លាននាក់។ នៅក្នុងពិភពលោកមួយដែលប្រឈមមុខនឹងវិបត្តិស្បៀងអាហារ និងទឹកកាន់តែច្រើនឡើង កិច្ចសហការគ្នាដើម្បីការពារ និងចែករំលែកធនធានធម្មជាតិដ៏សម្បូណ៌បែបរបស់ទន្លេមេគង្គ ជាជាងធ្វើឱ្យខូចខាតធនធានទាំងនេះ គប្បីគឺជាអាទិភាពខ្ពស់មួយ សម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងតំបន់។

## តើអង្គការទន្លេអន្តរជាតិកំពុងធ្វើអ្វី?

ក្នុងភាពជាដៃគូមួយនៃសម្ព័ន្ធការពារទន្លេមេគង្គ អង្គការទន្លេអន្តរជាតិ (International Rivers) និងសម្ព័ន្ធទន្លេកម្ពុជា (Rivers Coalition in Cambodia, RCC ) កំពុងខិតខំ លើកកម្ពស់ការយល់ដឹងសាធាណៈក្នុងតំបន់ និងអន្តរជាតិ អំពីហានិភ័យនានាទាក់ទិននឹងការទប់ទឹក ទន្លេអន្តរជាតិ ដ៏សំខាន់នេះ និង បង្ហាញថាមានវិធីប្រកបដោយនិរន្តរភាព និងសន្តិភាពជាងដើម្បីបំពេញសេចក្តី ត្រូវការថាមពល និងទឹករបស់ប្រជាជន។

## សូមចូលរួមជាមួយយើងខ្ញុំ!

**សំរាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រនៃអង្គការទន្លេអន្តរជាតិ** (International Rivers)**:**

internationalrivers.org **និង គេហទំព័រពហុភាសា :** savethemekong.org **។**

**ខែ មករា ឆ្នាំ ២០១១**